ការិយាល័យកណ្ដាល

# សេចក្ដីជូនដំណឹង

## ស្ដីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ("ធ.អ.ក") មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ទទួលជ្រាបថា ដោយអនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១** ធ.អ.ក នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ធនាគារ តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១** នៅម៉ោង **១៤:០០ រសៀល** នូវរបៀបវារៈដូចខាងក្រោម៖

១. អនុម័តលើការវិនិយោគនៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។

២. អនុម័តលើការផ្ទេរភាគហ៊ុនពី Triodos (TMF, TFSF, and TSFF) ទៅ North Haven Thai Private Equity Rumdul Company (Hong Kong) Limited។

៣. អនុម័ត និងទទួលស្គាល់ North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាភាគហ៊ុនិកថ្មីរបស់ ធ.អ.ក។

៤. អនុម័ត និងទទួលស្គាល់ លោក Ong Ling Wei មកពី North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាតំណាងភាគហ៊ុនិកថ្មីរបស់ ធ.អ.ក។

៥. អនុម័តលើការធ្វើវិសោធនកម្ម មាត្រា៧ ("ភាគហ៊ុនិក") និងមាត្រា៨ ("ការទិញភាគហ៊ុន") នៃលក្ខន្តិកៈរបស់ ធ.អ.ក។

៦. អនុម័តឲ្យក្រុមហ៊ុន Grant Thornton (GT) ធ្វើជាសវនករឯករាជ្យរបស់ ធ.អ.ក សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២២។

ភាគហ៊ុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១** នឹងទទួលបាននូវលិខិតអញ្ជើញ ឯកសារគាំទ្រ សេចក្ដីណែនាំអំពីការបោះឆ្នោតតាមប្រព័ន្ធ E-voting លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់ការបោះឆ្នោត ដែល ធ.អ.ក នឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួមការបោះឆ្នោតតាមកាលបរិច្ឆេទកំណត់បាន អាចផ្ដល់សិទ្ធិប្រទានទៅឲ្យអ្នកតំណាងណាម្នាក់ ដើម្បីបោះឆ្នោតជំនួស ដោយគ្រាន់តែជូនដំណឹងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ ធ.អ.ក **យ៉ាងយូរត្រឹមថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១** តាមរយៈមធ្យោបាយអេឡិចត្រូនិក។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

- ធ.អ.ក នឹងផ្ញើ QR Code សម្រាប់បោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗតាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង ១៤:០០ រសៀល (ម៉ោងនៅភ្នំពេញ)។
- ភាគហ៊ុនិកម្នាក់ៗ ត្រូវបោះឆ្នោតនៅ**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១** ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៤:០០ ដល់ម៉ោង ១៦:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់បោះឆ្នោត (សូមមើលសេចក្ដីណែនាំអំពីការបោះឆ្នោតតាមប្រព័ន្ធ E-voting ដែលនឹងផ្ញើជូនជាមួយ QR Code) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះតាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទដែលបានកំណត់ ដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ ធ.អ.ក ដូចខាងក្រោម៖

- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃអង្គារ ៧រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**